# សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា

ឱព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុតអើយ ការទ្រង់សុទ្ធតែធំ ហើយអស្ចារ្យ ឱស្តេចនៃគ្រប់ទាំងសាសន៍អើយ ផ្លូវទ្រង់សុទ្ធតែសុចរិត ហើយពិតត្រង់។ ឱព្រះអម្ចាស់អើយ តើមានអ្នកឯណាដែលមិនត្រូវកោតខ្លាចដល់ទ្រង់ ហើយសរសើរដំកើងដល់ព្រះនាមទ្រង់ ដ្បិតមានតែទ្រង់១ដែលបរិសុទ្ធ។(១)

ឯសេចក្តីកោតខ្លាច
ដល់ព្រះយេហូវ៉ានោះជាដើមចមនៃប្រាជ្ញា។ (២)

នោះហើយជាមូលហេតុដែលខ្ញុំទទួលស្គាល់ទ្រង់ក្នុងគ្រប់ទាំងផ្លូវ ហើយនឹងមិនពឹងផ្អែកលើយោបល់របស់ខ្លួនខ្ញុំឡើយ។ (៣)

មនុស្សដែលកោតខ្លាចដល់ព្រះយេហូវ៉ា នោះមានទីពឹងមាំមួន (៤) ប៉ុន្តែការដែលខ្លាចចំពោះមនុស្ស នោះនាំឲ្យជាប់អន្ទាក់វិញ។(៥)

ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានទុកចិត្តដល់ទ្រង់ទូលបង្គំបានថា ទ្រង់ជាព្រះនៃទូលបង្គំ។ (៦)

សេចក្តីមេត្រីរបស់ព្រះយេហូវ៉ានៅជាមួយនឹងអ្នកណាដែលកោតខ្លាចដល់ទ្រង់(៧) ដូច្នេះហើយទើបខ្ញុំកោតខ្លាចដល់ព្រះយេហូវ៉ាវិញ ហើយចៀសចេញពីសេចក្តីអាក្រក់ (៨) សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះចំរើនថ្ងៃអាយុ។ (៩)

(១) វិវរណៈ ១៥ : ៣-៤
(២) ទំនុកតម្កើង ១១១ : ១០
(៣) សុភាសិត ៣ : ៥-៦
(៤) សុភាសិត ១៤ : ២៦
(៥) សុភាសិត ២៩ : ២៥
(៦) ទំនុកតម្កើង ៣១ : ១៤
(៧) ទំនុកតម្កើង ២៥ : ១៤
(៨) សុភាសិត ៣ : ៧
(៩) សុភាសិត ១០ : ២៧

**វិវរណៈ ១៥ : ៣-៤** គេច្រៀងទំនុករបស់លោកម៉ូសេ ជាបាវបំរើនៃព្រះ និងទំនុករបស់កូនចៀមថា ឱព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុតអើយ ការទ្រង់សុទ្ធតែធំ ហើយអស្ចារ្យ ឱស្តេចនៃសាសន៍អើយ ផ្លូវទ្រង់សុទ្ធតែសុចរិត ហើយពិតត្រង់ ៤ ឱព្រះអម្ចាស់អើយ តើមានអ្នកឯណាដែលមិនត្រូវកោតខ្លាចដល់ទ្រង់ ហើយសរសើរដំកើងដល់ព្រះនាមទ្រង់ ដ្បិតមានតែទ្រង់១ដែលបរិសុទ្ធ គ្រប់ទាំងសាសន៍នឹងមកក្រាបថ្វាយបង្គំនៅចំពោះទ្រង់ ដ្បិតការសុចរិតរបស់ទ្រង់ បានសំដែងមកឲ្យឃើញហើយ។

**ទំនុកតំកើង ១១១: 10** ឯសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃប្រាជ្ញាអស់អ្នកដែលកាន់តាម នោះមានយោបល់ល្អ សេចក្តីសរសើរនៃទ្រង់ជាប់នៅអស់កល្បជានិច្ច។

**សុភាសិត ៣: ៥-៦** ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ៦ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង។

**សុភាសិត ១៤: ២៦** មនុស្សដែលកោតខ្លាចដល់ព្រះយេហូវ៉ា នោះមានទីពឹងមាំមួន ហើយកូនចៅរបស់គេនឹងបានទីពំនាក់ដែរ។

**សុភាសិត ២៩: ២៥** ការដែលខ្លាចចំពោះមនុស្ស នោះនាំឲ្យជាប់អន្ទាក់ តែអ្នកណាដែលទុកចិត្តដល់ព្រះយេហូវ៉ាពិត នោះនឹងបានសុខវិញ។

**ទំនុកតំកើង ៣១: ១៤** តែ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានទុកចិត្តដល់ទ្រង់ទូលបង្គំបានថា ទ្រង់ជាព្រះនៃទូលបង្គំ។

**ទំនុកតំកើង ២៥: ១៤** សេចក្តីមេត្រីមិត្ររបស់ព្រះយេហូវ៉ា នៅជាមួយនឹងអ្នកណាដែលកោតខ្លាចដល់ទ្រង់ ទ្រង់នឹងសំដែងឲ្យគេស្គាល់សេចក្តីសញ្ញារបស់ទ្រង់។

**សុភាសិត ៣: ៧** កុំឲ្យមើលខ្លួនថាមានប្រាជ្ញាឡើយ ចូរកោតខ្លាចដល់ព្រះយេហូវ៉ាវិញ ហើយចៀសចេញពីសេចក្តីអាក្រក់ទៅ ។

**សុភាសិត ១០: ២៧** សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះចំរើនថ្ងៃអាយុ តែអស់ទាំងឆ្នាំនៃអាយុរបស់មនុស្សអាក្រក់ នឹងត្រូវរួញខ្លីវិញ។


**បកប្រែដោយ: ONE -2- ONE CAMBODIA**

**អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**

**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**

www.One-2-One world.org

www.derekprince.co.nz PC06